

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ

សូមគោរពជូន
ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឱក មុន្នី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៨៥ ឈានចូល ៨៦ឆ្នាំ

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយក្តីរីករាយ ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៨៥ ឈានចូល ៨៦ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ១០រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៥ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ ជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងកាយមាំមួន បញ្ញាញាណ ភ្លឺថ្លា ជន្មាយុយឺនយូរ ដើម្បីរួមចំណែកជួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជាតិមាតុភូមិឱ្យកាន់តែរីកចម្រើនខ្លាំងក្លា និងសម្រេចបាននូវសមិទ្ធផលដ៏ត្រចះត្រចង់ថ្មីៗថែមទៀត។

នាឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពស្រឡាញ់យ៉ាងស្មោះស្ម័គ្រ ចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** ដែលកន្លងមកតែងបានខិតខំប្រឹងប្រែងលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត ក្នុងការកសាងប្រព័ន្ធច្បាប់ និងធ្វើឱ្យមានការរីកចម្រើនជាលំដាប់លើវិស័យច្បាប់ប្រកបដោយគតិបណ្ឌិត ដើម្បីបម្រើបុព្វហេតុ ជាតិ សាសនា ព្រះមហាក្សត្រ ធ្វើឱ្យមាតុភូមិកម្ពុជាទទួលបាននូវសុខសន្តិភាព ស្ថិរភាព សន្តិសុខសង្គមល្អប្រសើរ និងការអភិវឌ្ឍលើគ្រប់វិស័យ។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមលើកដៃប្រណម្យចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះព្រំនូវសព្ទសាធុការពរជ័យ ជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសម្រេចនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឱក មុន្នី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ៧កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០២៥
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ សីហា

វិថីហ្សុកនីមីហ្វ្រ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៨៤ email: generalsec@mod.gov.kh

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឱក មុន្នី
ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

អរគុណសន្តិភាព! អរគុណនយោបាយឈ្នះឈ្នះ!